Declassified to Public
06 September 2012

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧ — ០៦១-០៨

ដាក់ទៅ: អង្គបុរេជំនុំជម្រះ

ថ្ងៃដាក់: ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៧

ភាគីអ្នកដាក់: មេធាវីរបស់លោក កាំង ហ្កេកអ៊ាវ

ភាសាដើម: បារាំង

ប្រភេទឯកសារ: សាធារណៈ

---

## សំណើសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងសារណា នៃការជូនយោបល់តុលាការរបស់អ្នកមិនមែនជាភាគីក្នុងរឿងក្តីដែលពាក់ព័ន្ធនឹង បណ្តឹងឧទ្ធរណ៍លើដីកាសំរេចឃុំខ្លួនចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧

---

<u>អ្នកដាក់ឯកសារ:</u>

**មេធាវីរបស់លោក កាំង ហ្កេកអ៊ាវ**

លោកមេធាវី ការ សាវុត្ថ

លោកមេធាវី François ROUX

<u>អ្នកទទួលឯកសារ:</u>

**ចៅក្រមនៃអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ORIGINAL DOCUMENT
RECEIVED 25. OCT. 2007
AT 3.45
MAUREEN EDMONDS
CASE FILE OFFICER
MEdmonds.

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម
Certified Copy/Copie Conforme
ថ្ងៃទី(On/Le) 25 ខែ(Month/Mois) OCT
ឆ្នាំ (Year/Année) 2007
ក្រឡាបញ្ជី/ Greffier MEdmonds

1. កាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះបានជូនដំណឹងដល់អង្គការ និងសាធារណជននានាឲ្យបានជ្រាបថាពួកគេអាចផ្សព្វផ្សាយសារណានៃការជូនយោបល់តុលាការរបស់ខ្លួនដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីទៅលើដីកាសម្រេចឃុំខ្លួនលោកកាំង ហ្កេកអ៊ាវ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងនេះតទៅ។
2. រហូតទល់ថ្ងៃនេះ ពុំមានសារណានៃការជូនយោបល់តុលាការរបស់អ្នកមិនមែនជាភាគីក្នុងរឿងក្តីណាមួយត្រូវបានបញ្ជូនមកឲ្យមេធាវីការពារក្តីឡើយ ហើយគេកំពុងបកប្រែវា។
3. មេធាវីការពារក្តីសូមជំរាបជូនអង្គបុរេជំនុំជម្រះថានៅពេលដែលសារណានៃការជូនយោបល់តុលាការទាំងនោះ ជាភាសាបារាំង និងភាសាខ្មែរ បានបញ្ជូនមកដល់យើងខ្ញុំហើយ យើងខ្ញុំសូមឆ្លើយតបជាលាយល័ក្ខអក្សរទៅសារណាទាំងអស់ដែលអាចទាមទារឲ្យមានការឆ្លើយតបពីយើងខ្ញុំវិញនោះ ទៅលើចំណុចអង្គច្បាប់ រឺអង្គហេតុ។
4. អាស្រ័យហេតុនេះ តាមរយៈលិខិតនេះ មេធាវីការពារក្តីសូមការអនុញ្ញាតពីអង្គបុរេជំនុំជម្រះ ដើម្បីដាក់ចម្លើយតបជាលាយល័ក្ខអក្សរទាំងអស់ទៅសារណានៃការជូនយោបល់តុលាការរបស់អ្នកមិនមែនជាភាគីក្នុងរឿងក្តីដែលខ្លួនយល់ថាចាំបាច់ សម្រាប់សវនាការបណ្តឹងឧទ្ធរណ៍ស្តីពីការសម្រេចឃុំខ្លួនលោកកាំង ហ្កេកអ៊ាវ។
5. សហព្រះរាជអាជ្ញាបានធ្វើសំណើសុំស្រដៀងគ្នានេះដែរទៅអង្គបុរេជំនុំជម្រះ ("Co-prosecutors' request for leave to file responses to amicus curiae briefs submitted in the defence appeal of Kang Keck Iev alias Duch regarding provisional detention") ដែលបានដាក់កាលពីថ្ងៃទី៣ ខែតុលា នៅអង្គបុរេជំនុំជម្រះ និងបញ្ជូនមកឲ្យមេធាវីការពារក្តីនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៧។
6. នៅក្នុងបណ្តឹងសុំរបស់ខ្លួន សហព្រះរាជអាជ្ញាបានសុំការអនុញ្ញាត ដាក់ចម្លើយតបរបស់ខ្លួនក្នុងរយៈពេល១៥ថ្ងៃ គិតចាប់តាំងពីថ្ងៃដែលបានទទួលសារណានៃការជូនយោបល់តុលាការរបស់អ្នកមិនមែនជាភាគីក្នុងរឿងក្តី។
7. អាស្រ័យហេតុនេះ មេធាវីការពារក្តីសំណូមពរដល់អង្គបុរេជំនុំជម្រះមេត្តាយល់ព្រមផ្តល់ពេលឆ្លើយតបចំនួន១៥ថ្ងៃដល់យើងខ្ញុំដូចគ្នាដែរ ដោយគិតចាប់ពីថ្ងៃដែលបានទទួលសារណានៃការជូនយោបល់តុលាការរបស់អ្នកមិនមែនជាភាគីក្នុងរឿងក្តីជាភាសាបារាំង និងខ្មែរ។

| | | | |
|---|---|---|---|
| ថ្ងៃទី២៤<br>ខែតុលា<br>ឆ្នាំ២០០៧ | សម្រាប់មេធាវីទាំងពីរ<br>មេធាវីម្នាក់ក្នុងចំណោមមេធាវីទាំងពីរនាក់<br>មេធាវី **ការ សាវុត្ថ** | ភ្នំពេញ | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |